**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤១ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបាន បង្កើត **"គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន"** សរសេរជាអក្សរកាត់ថា **"គ.អ.វ."**។

## ជំពូកទី២

## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

**គ.អ.វ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១-ឧបនាយករដ្ឋមន្ត្រីប្រចាំការនិងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | អនុប្រធាន |
| ៤-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៧-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១០-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១១-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១២-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៣-រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤-រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៥-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប | សមាជិក |
| ១៦-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.អ.វ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

ដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ **គ.អ.វ.** អាចមានអនុគណៈកម្មាធិការ និងក្រុមការងារតាមវិស័យ ដែលត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ជំពូកទី៣**

**តួនាទីនិងភារកិច្ច**

**មាត្រា៤.-**

គ.អ.ទ. មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ធ្វើជាសេនាធិការឱ្យប្រមុខរាជរដ្ឋាភិបាលក្នុងការកំណត់ ការដឹកនាំ ការអនុវត្ត និងការតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណ លើចំណុចស្តីពីការអភិវឌ្ឍវិស័យឯកជន
- លើកនិងដាក់ឱ្យអនុវត្តនូវវិធានការកែលម្អបរិស្ថានវិនិយោគ
- លើកនិងដាក់ឱ្យអនុវត្តនូវវិធានការសម្របសម្រួលពាណិជ្ជកម្ម
- លើកនិងដាក់ឱ្យអនុវត្តនូវវិធានការជំរុញសហគ្រាសធុនតូចនិងមធ្យម
- លើកនិងដាក់ឱ្យអនុវត្តនូវវិធានការដទៃទៀត ដើម្បីជំរុញការអភិវឌ្ឍវិស័យឯកជន
- រាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីបណ្តាវិធានការនានាដែលបានដាក់ចេញ។ ក្នុងករណីមានវិធានការលើសពីសមត្ថកិច្ចរបស់ខ្លួន **គ.អ.ទ.** ត្រូវស្នើសុំការណែនាំនិងការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

**ជំពូកទី៤**

**ដំណើរការការងារ**

**មាត្រា៥.-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក **គ.អ.ទ.** ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

ក្នុងករណីប្រធានអវត្តមាន **គ.អ.ទ.** អាចដំណើរការប្រជុំ ក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៦.-**

**គ.អ.ទ.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមការងារបាន។

**គ.អ.ទ.** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់។

**មាត្រា៧.-**

**គ.អ.ទ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ជំពូកទី៥**

**អវសានប្បញ្ញត្តិ**

**មាត្រា៨.-**

ត្រូវបាននិរាករ ដូចតទៅ÷

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៣២ សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៥ ស្តីពីកំណែតម្រូវឈ្មោះគណៈកម្មការដឹកនាំការងារអភិវឌ្ឍន៍ផ្នែកឯកជននិងការបន្ថែមសមាសភាពសមាជិកនៃអនុគណៈកម្មាធិការសហគ្រាសធនតូចនិងមធ្យម
- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២៧ សសរ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ